- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម នស/រកម/០១៩៩/០១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការបែងចែកឥណទានថវិកាចំណាយតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការផ្ទេរចំណូល និងផ្ទេរឥណទានថវិកា សំរាប់ក្រសួងស្ថាប័នថ្មី
- យោងការសំរេចរបស់គណៈរដ្ឋមន្ត្រី នាថ្ងៃទី០២ ខែមេសា ឆ្នាំ ១៩៩៩

**សំរេច**

**មាត្រា ១ .-** ត្រូវបានអនុញ្ញាតអោយបន្ថែមប្រាក់បៀវត្ស ចំនួន ៣០ ភាគរយ លើបៀវត្សសុទ្ធសាធ ជូនមន្ត្រីរាជការស៊ីវិល យោធា នគរបាលជាតិ និវត្តជន និង មន្ត្រីបាត់បង់សមត្ថភាពពលកម្ម ។

**មាត្រា ២ .-** ប្រាក់បៀវត្សដែលបន្ថែម ៣០ ភាគរយនេះ ត្រូវចាប់អនុវត្ត ពីខែ ឧសភា ឆ្នាំ ១៩៩៩ តទៅ ។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន និង អភិបាលគ្រប់ខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យ នេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

**បានជំរាបជូន**

សម្តេចនាយករដ្ឋមន្ត្រីដើម្បីចុះហត្ថលេខា

ហត្ថលេខា

**គាត ឈន់**

ទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

***

## អនុក្រឹត្យលេខ ២៩ អនក្រ.បក

## ស្តីពីការកំណត់សមត្ថកិច្ចរបស់ខណ្ឌ ក្រុង

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពី របបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង
- យោងតាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា ១.-** ដោយអនុលោមទៅតាមមាត្រា ៥ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ខេត្ត ក្រុងជាអ្នកទទួលបន្ទុកគ្រប់គ្រងកិច្ចការផលប្រយោជន៍ ក្នុងមណ្ឌលដែនដីរបស់ខ្លួន ដើម្បីធានាអោយសេវាសាធារណៈ ដែលមិនស្ថិតនៅក្រោមការទទួលខុសត្រូវផ្ទាល់របស់រដ្ឋ ឆ្លើយតបទៅនឹងតំរូវការរបស់ប្រជាពលរដ្ឋក្នុងខេត្ត ក្រុង ។

**មាត្រា ២.-** នៅក្នុងក្របខ័ណ្ឌនៃបទបញ្ញត្តិនៃមាត្រា ១ ខាងលើនេះ ត្រូវបានប្រគល់អោយខេត្ត ក្រុង នូវសមត្ថកិច្ចនានា ដែលមានជាអាទិ៍ដូចខាងក្រោមនេះ ៖

**១-សមត្ថកិច្ចកិច្ចស្តីពីការរៀបចំផែនការ និង កម្មវិធីអភិវឌ្ឍន៍ :**

- រៀបចំផែនការអភិវឌ្ឍន៍ខេត្ត ក្រុង ដោយធ្វើសមាហរណកម្ម ទៅក្នុងក្របខ័ណ្ឌនៃផែនការរដ្ឋសំរាប់អភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ។
- ពិនិត្យរួមយោបល់ ទៅលើកម្មវិធី និងគំរោងនានាដែលរដ្ឋមានគោលបំណងធ្វើនៅខេត្ត ក្រុង
- រៀបចំកម្មវិធីអភិវឌ្ឍន៍ខេត្ត ក្រុងកំណត់នូវលក្ខខណ្ឌនៃហិរញ្ញប្បទាន និងអនុវត្តកម្មវិធីទាំងនោះ ។
- សំរបសំរួលកម្មវិធីរបស់ខេត្ត ក្រុង ជាមួយនឹងកម្មវិធីជាតិ ដែលមានការទាក់ទងដល់ខេត្ត ក្រុង

**២-សមត្ថកិច្ចស្តីពីការរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ :**

- រៀបចំគូសប្លង់គោលស្តីពីការរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ អោយស្របតាម ស្ថានភាពពិសេស នៃខេត្ត ក្រុងនិមួយៗ ក្នុងស្មារតីការពារដល់បេតិកភ័ណ្ឌ ដល់បរិស្ថាន ការពារធនធានធម្មជាតិ និងធានាដល់កិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម ។
- ផ្អែកតាមប្លង់គោលខាងលើ ត្រូវរៀបចំប្លង់ស្តីពីការប្រើប្រាស់ដីធ្លី និង សំណង់សំរាប់ខេត្ត ក្រុង ដោយបញ្ជាក់អោយច្បាស់អំពីតំបន់សំរាប់កសិកម្ម ពាណិជ្ជកម្ម ឧស្សាហកម្ម សិប្បកម្ម វប្បធម៌ ទេសចរណ៍ សាសនា លំនៅស្ថាន រដ្ឋបាល និង ទីធ្លាសាធារណៈ ។

- អនុញ្ញាតអោយកាន់កាប់នូវទ្រព្យសម្បត្តិដែលរដ្ឋផ្តល់អោយ ឬ ជាកម្មសិទ្ធិរបស់ខេត្ត ក្រុង ដោយទទួលបាននូវផលទុនពីទ្រព្យសម្បត្តិទាំងនោះ ក្នុងក្របខ័ណ្ឌនៃការប្រើប្រាស់ និង ពេលវេលាដែលត្រូវកំណត់ដោយដីការរបស់អភិបាលខេត្ត ក្រុង ។
- ផ្តល់លិខិតអនុញ្ញាតឯកត្តជននៃការរៀបជាជួរ និង លិខិតអនុញ្ញាតផ្សេងៗទៀតពាក់ព័ន្ធទៅនឹងផ្លូវថ្នល់ ជាទ្រព្យសម្បត្តិដែលរដ្ឋប្រគល់អោយ ឬ ជាកម្មសិទ្ធិរបស់ខេត្ត ក្រុង ។
- អនុញ្ញាតអោយកាន់កាប់ដីឡូត៍ សាងសង់ កែលំអ ជួសជុល រុះរើសំណង់ដែលស្ថិតនៅក្នុងដែនដីរបស់ ខេត្ត ក្រុង ។
- ពិនិត្យ និង ចាត់វិធានការតាមផ្លូវច្បាប់និងបទបញ្ជាជាធរមាន នូវបទល្មើសនៃការសាងសង់ ការរៀបជាជួរ ការពង្រាបផ្លូវថ្នល់ព្រមទាំងរាល់បទល្មើសទៅនឹងបទបញ្ញត្តិច្បាប់ និងបទបញ្ជាដែលទាក់ទងដល់ការរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ។

៣-សមត្ថកិច្ចស្តីពីការងារសាធារណការ :

- កសាង ជួសជុល ថែទាំផ្លូវគមនាគមន៍នៅជនបទ និងផ្លូវគមនាគមន៍ដែលរដ្ឋប្រគល់អោយខេត្ត ក្រុង គ្រប់គ្រង ។
- កសាង ជួសជុល ថែទាំផ្លូវនិងប្រឡាយទឹកសំរាប់វិស័យកសិកម្ម ។

៤-សមត្ថកិច្ចស្តីពីសេវាសាធារណៈ :

- រៀបចំបំភ្លឺទីសាធារណៈ និង ការផ្គត់ផ្គង់ទឹកស្អាត
- រៀបចំសណ្តាប់ធ្នាប់ចរាចរ និង ការដឹកជញ្ជូននៅក្នុងទីក្រុង និងក្នុងទីប្រជុំជននានា ។
- ចាត់វិធានការបង្ការ និងពន្លត់អគ្គិភ័យ
- រៀបចំការងារសុខាភិបាល និងអរ់រំដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ខេត្ត ក្រុង ។
- រៀបចំអោយមានអនាម័យ សុខភាព ការបោសសំអាត ការប្រមូលសំរាម និងសណ្តាប់ធ្នាប់សាធារណៈនៅក្នុងខេត្ត ក្រុង ។
- គ្រប់គ្រងទីផ្សារ និង សត្តឃាតដ្ឋាន ។
- រៀបចំបរិក្ខាកីឡា និង វប្បធម៌ ។
- រៀបចំសួនច្បារ និង ឧទ្យាន ។
- សង្គ្រោះចំពោះជនទីទ័លក្រ ជនអនាថា ។
- រៀបចំ និងគ្រប់គ្រងតំបន់ ដែលរដ្ឋផ្តល់អោយខេត្ត-ក្រុង ។

មាត្រា ៣ ._ អភិបាលខេត្ត ក្រុង ត្រូវរៀបចំនូវដីការ និង លិខិតបទដ្ឋាននានា ដើម្បីដាក់ចេញនូវវិធានការអនុវត្តជាក់ស្តែង នូវសមត្ថកិច្ចដូចមានចែងក្នុងមាត្រា ២ ខាងលើនេះ ដោយផ្អែកលើមូលដ្ឋាន នៃបទបញ្ញត្តិទាំងឡាយនៃច្បាប់ លិខិតបទដ្ឋានតាមផ្លូវច្បាប់ និង គោលនយោបាយរបស់រដ្ឋ ។

មាត្រា ៤ ._ ក្នុងករណីពិនិត្យឃើញដីកា លិខិតបទដ្ឋាន ឬសកម្មភាពណាមួយរបស់ខេត្ត ក្រុងធ្វើឡើងផ្ទុយនិងច្បាប់ លិខិតបទដ្ឋានតាមផ្លូវច្បាប់ និង គោលនយោបាយរបស់រដ្ឋ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចេញ

ប្រកាសលុបចោលដីកា លិខិតបទដ្ឋាន ឬ បញ្ឈប់សកម្មភាពនោះជាបន្ទាន់ ហើយបោតវិធានការណែនាំអោយបានត្រឹមត្រូវឡើងវិញ ។

មាត្រា ៥ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន អភិបាលគ្រប់ខេត្ត ក្រុងត្រូវទទួលអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១២ ខែមេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ដើម្បីចុះហត្ថលេខា

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង យូហុកគ្រី

★★★

# អនុក្រឹត្យលេខ ៣០ អនក្រ.បក

# ស្តីពីរបបរដ្ឋបាល ហិរញ្ញវត្ថុ និង ការប្រព្រឹត្តិទៅនៃរដ្ឋាករបស់ខេត្ត ក្រុង

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពី របបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង
- យោងតាមសំណើរបស់ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ